Ministry for Ethnic Communities
Te Tari Mātāwaka

# ឧទាហរណ៍ អំពីការជ្រៀតជ្រែកពីបរទេស

នេះគឺជាឧទាហរណ៍មួយចំនួន អំពីការជ្រៀតជ្រែកពីបរទេស ដែលសហគមន៍ជនជាតិភាគតិច បានជួបប្រទះ ដែលពួកគេបានចែករំលែកជាមួយក្រសួងកិច្ចការសហគមន៍ជនជាតិភាគតិច (Ministry for Ethnic Communities) ។ ឧទាហរណ៍ទាំងនេះ គឺផ្តល់ជូនសម្រាប់តែគោលបំណងផ្តល់ព័ត៌មាន និងការអប់រំតែប៉ុណ្ណោះ ។

នៅក្នុងឧទាហរណ៍ទាំងនេះ ពាក្យថា "រដ្ឋបរទេស" មានន័យថា**ប្រទេសណាមួយដែលមិនមែនជាប្រទេសនូវែលសេឡង់** ។ ពាក្យនេះត្រូវបានប្រើដើម្បីសំដៅទៅលើប្រទេសទាំងឡាយណាក្រៅពីប្រទេសនូវែលសេឡង់ ។

ហេតុការណ៍ដែលជ្រៀតជ្រែកដោយបរទេស អាចរាយការណ៍ទៅកាន់ NZSIS និងប៉ូលីស ។ ដើម្បីស្វែងយល់បន្ថែមអំពីការរាយការណ៍ សូមមើល ៖ របៀបរាយការណ៍បញ្ហាការជ្រៀតជ្រែកពីបរទេស ។

## ឧទាហរណ៍ទី 1

សមាជិកសហគមន៍ម្នាក់ បាននិយាយប្រឆាំងនឹងប្រទេសកំណើតរបស់ខ្លួន ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសនូវែលសេឡង់ ។ បន្ទាប់ពីហេតុការណ៍នេះបានកើតឡើង សមាជិកសហគមន៍រូបនោះបានទទួលទូរសព្ទពីធនាគាររបស់គាត់ នៅក្នុងប្រទេសនូវែលសេឡង់ ដោយគេបានប្រាប់ថា គណនីរបស់គាត់ ត្រូវបានបង្កក ដោយសារតែឈ្មោះរបស់គាត់ បានស្ថិតនៅក្នុងបញ្ជីអន្តរជាតិនៃមនុស្សដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ត្រង់នេះ ត្រូវគេហៅថា 'ការរឹតបន្តឹងផ្នែកធនាគារដោយមិនប្រាប់ដំណឹងជាមុន – debanking' ។ ពួកគេមិនអាចបើកលុយរបស់ពួកគេ ដែលផ្ញើទុកនៅធនាគារបានដោយសារគណនីធនាគាររបស់ពួកគេ ត្រូវបានបង្កក ។

សមាជិកសហគមន៍រូបនោះមានការព្រួយបារម្ភយ៉ាងខ្លាំងព្រោះគាត់មិនបានប្រព្រឹត្តបទល្មើសអ្វីឡើយ ។ ពួកគេជឿថា ឈ្មោះរបស់ពួកគេ ត្រូវបានដាក់ចូលក្នុងបញ្ជីដោយប្រទេសកំណើតរបស់គាត់ដើម្បីបំភិតបំភ័យពួកគេ និងបញ្ឈប់ពួកគេមិនឲ្យរិះគន់ប្រទេសកំណើតរបស់គាត់ទៀត ។ ពួកគេមានអារម្មណ៍ថាពួកគេគ្មានជម្រើសអ្វីក្រៅពីការឈប់និយាយរិះគន់ប្រទេសកំណើតរបស់ពួកគេ ។



## ឧទាហរណ៍ទី 2

បុគ្គលម្នាក់ដែលជាតំណាងរដ្ឋាភិបាលបរទេស បានចូលមកទាក់ទងសមាជិកសហគមន៍ម្នាក់ ។ បុគ្គលនោះ បានប្រាប់សមាជិកសហគមន៍រូបនេះថា គ្រួសាររបស់គាត់ នៅក្នុងប្រទេសកំណើតរបស់គាត់ នឹងស្ថិតក្នុងគ្រោះថ្នាក់ ប្រសិនបើគាត់មិនព្រមចូលរួមក្នុងក្រុមដែលរៀបចំដោយរដ្ឋាភិបាលបរទេសនោះទេ ។ គោលបំណងរបស់ក្រុមនេះ គឺដើម្បីផ្សព្វផ្សាយសារនយោបាយនៅក្នុងសហគមន៍របស់ពួកគេ នៅក្នុងប្រទេសនូវែលសេឡង់ ក្នុងនាមរដ្ឋបរទេស ។ សមាជិកសហគមន៍រូបនោះ មិនចង់ចូលរួមក្នុងក្រុមនោះទេ ប៉ុន្តែគាត់ខ្លាចថាក្រុមគ្រួសាររបស់គាត់មានគ្រោះថ្នាក់ និងមានអារម្មណ៍ថា បានរងគំនាប់ឱ្យចូលក្រុមនោះ ដើម្បីសុវត្ថិភាពគ្រួសាររបស់គាត់ ។

ការត្រូវបានបង្ខំឱ្យចូលរួមក្រុមនោះ បានធ្វើឱ្យសមាជិកសហគមន៍រូបនោះ មានអារម្មណ៍ថាគាត់កំពុងស្ថិតក្នុងការគំរាមកំហែង និងមិនមានសុវត្ថិភាពក្នុងជីវិតរស់នៅឡើយ ។ សមាជិកសហគមន៍រូបនេះ ត្រូវប្រាកដខ្លួនឯងថា គាត់មិននិយាយអ្វីដែលបង្ហាញថាគាត់មិនគាំទ្រក្រុមនោះឡើយ ។ គាត់ មានអារម្មណ៍ថា មិនអាចបង្ហាញពីទស្សនៈពិតរបស់ខ្លួនបាន ។ សេរីភាពនៃការបញ្ចេញមតិរបស់គាត់ត្រូវបានគេដកហូត ។

## ឧទាហរណ៍ទី 3

សហគមន៍ជនជាតិមួយកំពុងរៀបចំព្រឹត្តិការណ៍វប្បធម៌ ។ មានបុគ្គលម្នាក់ ដែលជាអ្នកតំណាងរដ្ឋាភិបាលនៃប្រទេសកំណើតរបស់អ្នករៀបចំព្រឹត្តិការណ៍នោះ បានផ្តល់ជំនួយថវិកាយ៉ាងច្រើនដល់គាត់ ។ បុគ្គលនោះ បាននិយាយថា គេនឹងប្រគល់ជំនួយថវិកានោះដល់គាត់ (អ្នករៀបចំព្រឹត្តិការណ៍) តែគឺជាថ្នូរនឹងការចែករំលែកព័ត៌មានអំពីសមាជិកក្នុងសហគមន៍នោះ ។

អ្នករៀបចំព្រឹត្តិការណ៍នោះ មិនមានអារម្មណ៍ស្រួលក្នុងខ្លួនឡើយពេលប្រឈមនឹងស្ថានភាពបែបនេះ ។ គាត់មានអារម្មណ៍ថាស្ថិតក្រោមសម្ពាធ ក្នុងការទទួលយកជំនួយថវិកានោះ សម្រាប់រៀបចំព្រឹត្តិការណ៍នោះ ដោយធាតុពិត គឺគាត់មិនចង់ចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់សមាជិកសហគមន៍នោះទេ ។ តែនៅពេលគាត់បដិសេធមិនទទួលយកជំនួយថវិកានោះ គាត់មានការភ័យខ្លាច ។ គាត់ព្រួយបារម្ភអំពីអ្វីដែលអាចកើតឡើងចំពោះគាត់ ដោយសារការបដិសេធមិនទទួលយកជំនួយថវិកា ។ វាធ្វើឲ្យគាត់មានអារម្មណ៍មិនស្រណុកក្នុងចិត្ត នៅក្នុងសហគមន៍របស់គាត់ ។

## ឧទាហរណ៍ទី 4

មានសមាជិកសហគមន៍ម្នាក់ កំពុងជួបបញ្ហាហិរញ្ញវត្ថុ ។ មានបុគ្គលម្នាក់ នៅក្នុងសហគមន៍របស់គាត់ បានទាក់ទងគាត់ ក្នុងនាមរដ្ឋបរទេស ដើម្បីផ្តល់ការងារឱ្យគាត់ធ្វើ ។ ការងារនោះគឺការតាមដានសមាជិកសហគមន៍ នៅប្រទេសនូវែលសេឡង់ ហើយរាយការណ៍ ទៅរដ្ឋបរទេស ។ ពួកគេចង់ដឹងថា នរណាខ្លះដែលរិះគន់រដ្ឋបរទេសនោះ ។

ស្ថានភាពនេះ បានធ្វើឲ្យសមាជិកសហគមន៍រូបនេះ មានអារម្មណ៍ទុក្ខព្រួយក្នុងចិត្ត ។ គាត់មិនចង់ធ្វើជាអ្នកចាំតាមដានសហគមន៍របស់គាត់ឡើយ ។ គេបានយកបញ្ហាហិរញ្ញវត្ថុរបស់គាត់ មកប្រើប្រាស់ដើម្បីបង្ខិតបង្ខំគាត់ ។ គាត់បានបដិសេធ ប៉ុន្តែគាត់មានការព្រួយបារម្ភថាតើនឹងមានអ្វីមិនល្អអាចកើតឡើងចំពោះគាត់ដែរឬទេ ចំពោះការបដិសេធនោះ។ គាត់ក៏បានចាប់ផ្តើមដកខ្លួនឲ្យឆ្ងាយពីសហគមន៍ ដោយបារម្ភថាបុគ្គលនោះ អាចមកទាក់ទងគាត់ម្តងទៀត ។ គាត់ក៏បាត់បង់ការជឿទុកចិត្តលើមនុស្សនៅក្នុងសហគមន៍ផងដែរ ដោយមានអារម្មណ៍មិនប្រាកដចិត្តថាតើមានអ្នកណាខ្លះទៀត ដែលពាក់ព័ន្ធក្នុងសកម្មភាពទាំងនេះ ។